ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ...០២៧/២៣.......រ.ប.ក

# របាយការណ៍ខែធ្នូ
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែមករា ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេស រុស្ស៊ី និង ប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ ហេតុធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ ហេតុដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

**១. ការកសាងច្បាប់**

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** ៖ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

**២. សន្ធិសញ្ញា**

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

### ខ. ការបង្ការ ទប់ស្កាត់

**១. តាមរយៈការលើកកម្ពស់ការយល់ដឹង**

**១.១. ការអប់រំដោយផ្ទាល់**

**១.១.១. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)** បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធប្រារព្ធ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ «**រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព**» ដែលមានការគោរពអញ្ជើញដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួមសរុបប្រមាណ ៣០០០អង្គ/នាក់។

- **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត** ចំនួន ០៧ រួមមាន៖ ខេត្តកណ្តាល ស្វាយរៀង កំពង់ចាម កែប សៀមរាប កោះកុង និងខេត្តឧត្តរមានជ័យ បានសហការជាមួយអង្គការដៃគូរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ «**រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព**» និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន **០៧**លើក មនុស្សប្រមាណ ៣.៩៤១អង្គ/នាក់ (**ស្រី ១.៤៨២**នាក់)។

### ១.១.២. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

នៅក្នុងខែធ្នូ ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយ អង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព និងរៀបចំវេទិកាសាធារណៈការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ សរុបចំនួន **១២.៥២៣**លើក មានអ្នកចូលរួមសរុបចំនួន **៥៣០.៩២៧**នាក់ (ធៀបនឹងខែវិច្ឆិកា មានចំនួន **៥១០.៧៣៦**នាក់ គឺមានការកើនឡើងចំនួន **២០.១៩១**នាក់ ស្មើនឹង**៣,៩៥%**) ក្នុងនោះស្ត្រីចំនួន **២៤០.៤២៩**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ២៤ | ៣.០៥៨ | ១.៦០៨ | ៥៨៥ | ២១.៨៩៤ | ៩.៨៧៧ |
| សរុប ក្រសួង ស្ថាប័ន | | ២៤ លើក | ៣.០៥៨ នាក់ | ១.៦០៨ នាក់ | ៥៨៥ លើក | ២១.៨៩៤ នាក់ | ៩.៨៧៧ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ១.០៣៤ | ៥៥.៩៩០ | ២៨.៦៣៣ | ១.៩៦៤ | ១៤៥.១៤៧ | ៤៧.៣២១ |
| ៣ | ខេត្តបាត់ដំបង | ៨៣៩ | ៣៤.៥៦៦ | ១៩.៧០៩ | ៥៩០ | ១៧.៥៥១ | ១០.១៩២ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៧០ | ២៦.១១១ | ១៤.៤១០ | ១១៨ | ៣.៤៦៤ | ១.៦៧៧ |
| ៥ | ខេត្តសៀមរាប | ១៥៨ | ៩.៥៧៩ | ៣.៤០១ | ៧៣ | ៣.៧២៨ | ២.១២៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៩៥៦ | ២១.១៦៨ | ១០.៩៧៣ | ៥២៦ | ១០.២៨៥ | ៥.១៩១ |
| ៧ | ខេត្តកំពង់ចាម | ១.៧២៣ | ៩១.៤៦០ | ៤៧.០៣៦ | | | |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ៦ | ១.៦៥៩ | ៩០០ | | | |
| ១០ | ខេត្តស្វាយរៀង | ១ | ១៥ | ១០ | ៣១៥ | ១៣.៦១៣ | ៧.០៧៩ |
| ១១ | ខេត្តប៉ៃលិន | ៧០ | ១.៣១២ | ១៨៦ | ២៨ | ១.១០២ | ២៧១ |
| ១២ | ខេត្តកោះកុង | | | | ៦៥ | ១.៣២៨ | ៥៩៩ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ៣៥១ | ២៤.១៣៧ | ១១.៨៩៦ | ២១ | ១.២៥៥ | ៥០៨ |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ១៣ | ៥១០ | ៤១៧ | | | |
| ១៧ | ខេត្តកែប | ២៨ | ៥.៣៩៥ | ២.២៣៤ | ៣៩ | ១.៣៩៤ | ៧០៨ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ១៤ | ២.២៨២ | ៤៨៤ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៤ | ១.០៨៧ | ៤៧២ | ២.៣៥៨ | ២៨.៧១៨ | ១១.០២៧ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៥១ | ១.៩៥៦ | ៩៦៤ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ៩៩ | ១.១៦៣ | ៥២១ | | | |
| សរុប រាជធានី-ខេត្ត | | ៥.៨១៧លើក | ២៧៨.៣៩០នាក់ | ១៤២.២៤៦នាក់ | ៦.០៩៧លើក | ២២៧.៥៨៥នាក់ | ៨៦.៦៩៨នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ១២.៥២៣ លើក | | ចំនួនមនុស្សសរុប ៥៣០.៩២៧ នាក់ | | ចំនួនស្ត្រី ២៤០.៤២៩ នាក់ | |

១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តកណ្ដាល៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការប្រជុំណែនាំ គណៈមេប្រយោគប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងតាមរយៈកិច្ចប្រជុំត្រៀមរៀបចំបើកបវេសនកាល ឆ្នាំសិក្សា២០២២-២០២៣ មានអ្នកចូលរួមសរុប **៣១៨**នាក់ ស្រី**០២**នាក់ នៅសាលាគុរុកោសល្យ និងវិក្រឹត្យការខេត្តកណ្ដាល។
- **ខេត្តសៀមរាប៖**
  - **មន្ទីរទេសចរណ៍៖** បានចុះពង្រឹង និងទប់ស្កាត់ការជួញដូរមនុស្សមនុស្ស ក្នុងវិស័យទេសចរណ៍នៅតាមអាជីវកម្មស្នាក់នៅ ម៉ាស្សានិងស្ប៉ា ឌីស្កូតែក និងKTV បៀហ្គាឌិន បានចំនួន **២០**លើក មានអ្នកចូលរួមសរុប **១៧៣**នាក់ ស្រី**១៥០**នាក់។
  - **មន្ទីរឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖** បានធ្វើការបញ្ជ្រាបការផ្សព្វផ្សាយអំពីអំពើជួញដូរមនុស្ស នៅក្នុងដំណើរការជំរុញនិងលើកទឹកចិត្តដល់សហគ្រិនឱ្យបានយល់ដឹងអំពីសារៈសំខាន់នៃដំណើរការអាជីវកម្ម បានចំនួន១៩មូលដ្ឋាន អ្នកចូលរួម ១៩នាក់ ស្រី០៨នាក់។
  - **មន្ទីរអប់រំ យុវជន និងកីឡា៖** បានបញ្ជ្រាបផ្សព្វផ្សាយនៅក្នុងការបណ្ដុះបណ្ដាលការងារស្ម័គ្រចិត្តស្ដីពីការរំលោភបំពានកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ការប្រើប្រាស់គ្រឿងញៀន **០១លើក** មានអ្នកចូលរួម **៨០**នាក់ ស្រី**៥៩**នាក់។ និងសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) ផ្សព្វផ្សាយអំពីហានិភ័យនៃការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ដល់និស្សិតនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាខេត្តសៀមរាប **០១លើក** មានអ្នកចូលរួម **៤៦**នាក់ ស្រី**២៥**នាក់។
- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្សតាមរយៈកិច្ចតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្សនៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនសាលាផងដែរ។
- **ខេត្តបន្ទាយមានជ័យ៖** លោកស្រី **រស់ សុផានី** ប្រធានលេខាធិការដ្ឋាន បានចូលរួមជាគណៈអធិបតីក្នុងពិធីសម្ពោធអគារសិក្សានិងសមិទ្ធិផលនានារបស់អង្គការសម្រេចសុបិនកុមារកម្ពុជា នៅស្រុកព្រះនេត្រព្រះ និងបានចូលរួមក្នុងកម្មវិធីចុះពិនិត្យព្យាបាលជំងឺទូទៅដោយមិនយកកម្រៃ ជូនប្រជាពលរដ្ឋនៅស្រុកមង្គលបូរី ហើយបានបញ្ជ្រាបអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋសរុប **៧៤០**នាក់ ស្រី**៤៥៤**នាក់។
- **ខេត្តកំពង់ចាម៖**
  - **រដ្ឋបាលក្រុង ស្រុកទាំង១០៖** បានអប់រំផ្សព្វផ្សាយទៅតាមរយៈការប្រជុំគ.ស.ន.ក និងគ.ក.ន.ក ពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈទៅលើស្ត្រីនិងកុមារ និងបញ្ហាចំណាកស្រុកទៅរកការងារធ្វើ ចៀសវាងការចាញ់បោកមេខ្យល់ ។
  - **មន្ទីរអប់រំយុវជន និងកីឡាខេត្ត៖** ចូលរួមផ្សព្វផ្សាយតាមរយៈក្រុមការងារ ស្ដីពីការលើកម្ពស់សុខភាពសិក្សា និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមសាលារៀនទូទាំងខេត្ត។

១.១.៤. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តសៀមរាប៖ អង្គការមូលនិធិអេ២១** ធ្វើការផ្សព្វផ្សាយដល់សហគមន៍ បានចំនួន **០៥**លើក មានអ្នកចូលរួមសរុប ៨៤០នាក់ ស្រី**៣៧៨**នាក់។

• **ខេត្តបន្ទាយមានជ័យ៖**

- **អង្គការដំណក់ទឹក** បានចុះធ្វើបណ្តុលយចល័តអប់រំដល់កុមារស្តីពីសិទ្ធិកុមារទាំង៤ និងចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន០២លើក អ្នកចូលរួមសរុប **២៤៧**នាក់ ស្រី**១៣៩**នាក់ និងបានចុះធ្វើសកម្មភាពប្រជុំលើកកម្ពស់ការយល់ដឹងអប់រំ ដល់ក្រុមយុវជន និងគ្រួសារស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ០១លើក អ្នកចូលរួម **៥៥**នាក់ ស្រី**៣១**នាក់។
- **អង្គការកល្យាណមិត្ត** បានចុះធ្វើកម្មវិធីអប់រំផ្សព្វផ្សាយបំណិនជីវិត ស្តីពីការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងចែកសម្ភារៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **២០៤**នាក់ ស្រី**១២១**នាក់។

**១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

• ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន **១.០៧៩**នាក់។

• **ខេត្តសៀមរាប៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ **១៣០**លើក និងផ្សាយផ្ទាល់ស្តីពីការប្រារព្ធទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ នៅលើហ្វេសប៊ុកផេកទូរទស្សន៍ជាតិខេត្ត មានអ្នកចូលមើល **១,២៣៩**ដង។

• **ខេត្តព្រៃវែង៖** មន្ទីរពត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ ៥០លើក។

**១.៣. ការផ្សព្វផ្សាយតាមរយៈខួបករណ៍**(IEC)

• **ខេត្តសៀមរាប៖**

- **រដ្ឋបាលស្រុកពួក** បានធ្វើការផ្សព្វផ្សាយ និងចែកខិតប័ណ្ណស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព បានចំនួន ៥០ខិត្តប័ណ្ណ។
- **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចែកខិតប័ណ្ណ សម្រាប់ផ្តល់ព័ត៌មានអំពីលេខទូរស័ព្ទក្នុងការទំនាក់ទំនងដែលអាចរាយការណ៍សុំកិច្ចអន្តរាគមន៍ ក្នុងករណីបានឃើញ ឬបានជួបប្រទះអំពើហិង្សា អំពើជួញដូរមនុស្ស ឬការរំលោភបំពានលើស្រ្តីពលករចំណាកស្រុក ដល់ប្រជាពលរដ្ឋនិងអាជ្ញាធរស្រុកក្រឡាញ់(កម្មវិធីសុវត្ថិភាព និងយុត្តិធម៌) ចំនួន ៣០០សន្លឹក។

• **ខេត្តបាត់ដំបង៖** **អង្គការសាម៉ារីតាន់ភឺស** ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព បានចំនួន **១២៦**នាក់(ស្រី**៥៨**នាក់) កុមារ ០៤នាក់(កុមារី០២នាក់)។

• **ខេត្តបន្ទាយមានជ័យ៖**

- **អង្គការសាម៉ារីតាន់ភឺស** ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើ ចំណាកស្រុកដោយសុវត្ថិភាពចំនួន ៧៨១នាក់(ស្រី២៥២នាក់) កុមារ ៨៨នាក់(កុមារី៤២នាក់)។
- **អង្គការ** IOM បានចែកសម្ភារៈជូនដល់ជនទេសន្តប្រវេសន៍វិលត្រលប់មកកម្ពុជាវិញ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព បានចំនួន **៥៦**នាក់ ស្រី **១៨**នាក់។

**១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **ខេត្តកំពង់ចាម៖** ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងវិទ្យុចំនួន ០១លើក ក្រោមប្រធានបទ៖ការការពារ សុវត្ថិភាពស្ត្រីនិងកុមារក្នុង វិស័យទេសចរណ៍។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

• **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការចុះអធិការកិច្ចជនបរទេសបានចំនួន ០៨សហគ្រាស ពិនិត្យឃើញមានជនបរទេសចំនួន ០៩នាក់ ស្រី០៣នាក់ ក្នុងនោះអ្នកមានប័ណ្ណនិងសៀវភៅការងារ ០៧នាក់ ស្រី០៣នាក់ និងគ្មានប័ណ្ណនិងសៀវភៅការងារ០២នាក់។

- **ខេត្តបាត់ដំបង៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះធ្វើអធិការកិច្ចការងារ និងជំរុញផ្សព្វផ្សាយការអនុវត្តច្បាប់ ស្តីពីការងារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធវិស័យការងារ នៅតាមរោងចក្រសហគ្រាសចំនួន ៥៤ មានកម្មករនិយោជិតសរុប ១.១៦០នាក់ ស្រី ៥៧៦នាក់ ក្នុងនោះកម្មករនិយោជិតជាជនបរទេសមានចំនួន ១៥នាក់ ស្រី ០៥នាក់។

**២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក**

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ២៣០.៣៣១នាក់ (ស្រី ១០១.៦៦០នាក់) អនីតិជន ៣.៣៨០នាក់(ស្រី១.១៨៨នាក់) ក្នុងនោះមាន៖
  - ស្របច្បាប់ ចំនួន ១៧២.៩៦០នាក់ (ស្រី៧៧.០៥៦នាក់) អនីតិជន ៣៣៥នាក់(ស្រី១០៣នាក់)
  - មិនស្របច្បាប់ចំនួន ៥៦.៦៨៨នាក់ (ស្រី ២៤.៣០៩នាក់) អនីតិជន ២.៩៤១នាក់ (ស្រី ១.០៥៦នាក់)។
  - ដាច់ការទាក់ទងចំនួន ៦៨៣នាក់ (ស្រី ២៧៩នាក់) អនីតិជន ១០៤នាក់(ស្រី២៩)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ៨០.៧៤៤នាក់ (ស្រី៣៤.៥៣៩នាក់) អនីតិជន ៤៤៩នាក់ (ស្រី ១៦៤នាក់)។
- **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន ០១លើក មនុស្សចំនួន ២២នាក់(ស្រី ១២នាក់) អនីតិជន ០៤នាក់ បានធ្វើកិច្ចសន្យាអប់រំ ណែនាំរួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

**២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ កំពង់ឆ្នាំង កែប កំពង់ស្ពឺ ស្វាយរៀង និងខេត្តបន្ទាយមានជ័យ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ១៥៦គោលដៅ មនុស្សចំនួន ៥៨៤នាក់(ស្រី៤៣៥នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង ព្រះវិហារ តាកែវ និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន ២១លើក។

**២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ បានចំនួន ១៥១នាក់(ស្រី១៨នាក់) មាន ១៤សញ្ជាតិ ហើយបានវាយតំលៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយបានចំនួន ១១៥នាក់(ស្រី១៤នាក់)។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមរយៈទូរស័ព្ទ ចំនួន ០៨នាក់(ស្រី០៥នាក់) មានសេចក្តីសុខធម្មតា។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារនៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ចំនួន ០១លើក។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រ សហគ្រាស កន្លែងលាងឡាន កន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ ០-៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ០៩ករណី (ធៀបនឹងខែវិច្ឆិកា មានចំនួន **១២**ករណី ថយចុះ **០៣**ករណី ស្មើនឹង **២៥%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **១២**នាក់(ស្រី**០៤**នាក់) ជនសង្ស័យជាជនបរទេស**០១**នាក់ (ជនជាតិអាឡឺម៉ង់)។

សង្គ្រោះជនរងគ្រោះ ចំនួន **៣០**នាក់(ស្រី**២២**នាក់) មាន: អាយុក្រោម១៥ឆ្នាំ **០៧**នាក់ អាយុ១៥-១៧ឆ្នាំ **០៣**នាក់ និងអាយុ១៨ឆ្នាំឡើង **២០**នាក់ (ប្រគល់ឱ្យសង្គមកិច្ច **២៦**នាក់ និងប្រគល់ឱ្យគ្រួសារ **០៤**នាក់) ក្នុងនោះបែកជា:

❖ **ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **០៣/០៣**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **០៣**នាក់(ស្រី**០២**នាក់)។ សង្គ្រោះជនរងគ្រោះចំនួន **១៦**នាក់(ស្រី**០៨**នាក់) មាន: អាយុក្រោម១៥ឆ្នាំ **០២**នាក់ និងអាយុ១៨ឆ្នាំឡើង **១៤**នាក់ (ប្រគល់ឱ្យគ្រួសារ **១៦**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ០២ | ១៥ (០៧) | ០២ |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ (០១) | ០១ |
| *សរុប* | *០៣ ករណី* | *១៦ (០៨) នាក់* | *០៣ នាក់* |

❖ **ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **០៦/០៩**ករណី ឃាត់ខ្លួនជនសង្ស័យចំនួន **០៩**នាក់(ស្រី**០២**នាក់) ជនសង្ស័យជាជនជាតិអាឡឺម៉ង់ **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **១៤**នាក់(ស្រី**១៤**នាក់) មាន: អាយុក្រោម១៥ឆ្នាំ **០៥**នាក់ អាយុ១៥-១៧ឆ្នាំ **០៣**នាក់ និងអាយុ១៨ឆ្នាំឡើង **០៦**នាក់ (ប្រគល់ឱ្យសង្គមកិច្ច **១០**នាក់ ប្រគល់ឱ្យគ្រួសារ **០៤**នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០១ | ០៨ (០៨) | ០១ |
| -សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០២ (០២) | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ (០២) | ០៤ |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ (០២) | ០២ |
| *សរុប* | *០៦ ករណី* | *១៤ (១៤) នាក់* | *០៩ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន **២៣**នាក់(ស្រី**២២**នាក់) អនីតិជន០២នាក់ មកពីប្រទេសចិន២២នាក់ និងម៉ាឡេស៊ី០១នាក់ ករណីរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធម្មជាតិ២១នាក់ និងស្នាក់នៅខុសច្បាប់០២នាក់។

- **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាល បានទទួល និងសម្ភាសពលករខ្មែរចូលតាមច្រកអូរបើជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោតប៉ែត ចំនួន **៣៩**លើក មនុស្សចំនួន **៨៧៦**នាក់ (ស្រី**២៧២**នាក់) អនីតិជន **១០១**នាក់។
- **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **០៧**លើក មនុស្សចំនួន **០៩**នាក់(ស្រី**០១**នាក់)។
- **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន **០១**លើក មនុស្សចំនួន **១៥**នាក់(ស្រី**១០**នាក់) អនីតិជន **១១**នាក់(ស្រី**០៨**នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

- **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាព ការងារ និងការជួយសង្គ្រោះបឋម ចំនួន០៥វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៨៨នាក់ ស្រី ៦៤ នាក់ ។

- **ខេត្តត្បូងឃ្មុំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយ អង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រីនិងកុមារ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី យេនឌ័រ និងការធ្វើចំណាកស្រុកទៅប្រទេសចិន តាមរយៈការរៀបអាពាហ៍ពិពាហ៍ ចំនួន ០១វគ្គ មានអ្នកចូលរួម ៨៩នាក់ ស្រី ៣៦នាក់ ។

- **ខេត្តសៀមរាប៖ លេខាធិការដ្ឋាន គ.ខ.ប.ជ** សហការជាមួយ អង្គការដែនដីមនុស្ស-ហូឡង់កម្ពុជា (TDH) បើកវគ្គបណ្តុះបណ្តាលស្តីពី **ការថែទាំដោយផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត** បានចំនួន០១វគ្គ ដល់សមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក មានអ្នកចូលរួមចំនួន **៤៥**នាក់ ស្រី **២៩**នាក់។

- **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋានគ.ខ.ប.ជ សហការជាមួយ អង្គការជំនួយផ្លូវច្បាប់ដល់ស្រីនិងកុមារ (LSCW) បើកវគ្គបណ្តុះបណ្តាលស្តីពី យន្តការទទួលពាក្យបណ្តឹង និងគោលការណ៍ណែនាំសំរាប់អ្នកដោះស្រាយវិវាទពលករ **០១**លើក មានសិក្ខាកាម **៤២**នាក់ ស្រី**២៦**នាក់។

- **ខេត្តកោះកុង៖** មន្ទីរទេសចរណ៍ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្មក្នុងវិស័យទេសចរណ៍ ០១លើក មានអ្នកចូលរួម **៣៥**នាក់។

#### ២. សិក្ខាសាលា

- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការប្រមូលធាតុចូល ការអនុវត្តល្អៗ កត្តាប្រឈម និងអនុសាសន៍សម្រាប់ការឆ្លើយតបទៅនឹងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បានចំនួន **០១**លើក មានអ្នកចូលរួម **៥០**នាក់ ស្រី **២៨**នាក់។
- **ខេត្តកណ្តាល៖** គ.ខ.ប.ជ សហការជាមួយ អង្គការក្តីសង្ឃឹម និងយុត្តិធម៌ រៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការប្រមូលធាតុចូលដើម្បីរៀបចំកម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ០១លើក មានអ្នកចូលរួម ៤០នាក់ ស្រី ១១នាក់។

### ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

#### ១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- **ខេត្តសៀមរាប៖ លេខាធិការដ្ឋាន គ.ខ.ប.ជ** បានសហការជាមួយមន្ទីរធម្មការ និងសាសនា បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា ដល់ថ្នាក់ដឹកនាំអន្តរសាសនានៅក្នុងខេត្តសៀមរាប បានចំនួន០១លើក មានអ្នកចូលរួម **៦០**អង្គ/នាក់ ស្រី **១៥**នាក់។

២. **ការងារជំនួបពិភាក្សា**

- **ខេត្តបន្ទាយមានជ័យ៖** លោកស្រី **រស់ សុផានី** ប្រធានលេខាធិការដ្ឋាន និងក្រុមការងារ បានជួបពិភាក្សាជាមួយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រីនិងកុមារ ស្តីពីការអនុវត្តគម្រោងយុត្តិធម៌សម្រាប់ពលករចំណាកស្រុកក្នុងវិស័យនេសាទ និងកែច្នៃអាហារសមុទ្រ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត មានអ្នកចូលរួម **១២**នាក់ ស្រី**០៥**នាក់។ និងបានចូលរួមកិច្ចសម្ភាសន៍ ជូនក្រុមការងារវាយតម្លៃគម្រោងស្តីពី សុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា តាមប្រព័ន្ធអនឡាញ អ្នកចូលរួម **០៥**នាក់ ស្រី**០៣**នាក់។
- **ខេត្តកំពង់ចាម៖** លោកជំទាវ **ប៉ាង ដានី** ប្រធានលេខាធិការដ្ឋាន និងសមាជិក សមាជិកាបានជួបពិភាក្សាជាមួយលោក **តូនី ផ្ទុណិត** នាយកការិយាល័យអង្គការរតនៈអ៊ីនធើណេសិនណល ប្រចាំប្រទេសកម្ពុជា និងក្រុមការងារ ស្តីពីកិច្ចសហការសម្រាប់ការអនុវត្តគម្រោង "បង្ការទប់ស្កាត់ភាពងាយរងគ្រោះនៃអំពើជួញដូរមនុស្ស" មានអ្នកចូលរួម **២៣**នាក់ ស្រី**១៨**នាក់។
- **ខេត្តកណ្តាល៖** ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាល នៃគណៈអភិបាលខេត្ត បានជួបពិភាក្សាជាមួយអភិបាលក្រុង Choi Dinh-in of Heupect នៃសាធារណរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងការជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅសាធារណៈរដ្ឋកូរ៉េ នៅសាលាខេត្តកណ្តាល។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសចំនួន **៦៨**លើក មានអ្នកចូលរួមសរុប **១.០៨២**នាក់(ស្រី**៣៩០**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **២២**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត **៤៦**លើក។**(ឧបសម្ព័ន្ធ១)**

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។

- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមករា ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ...អង្គារ ២រោច...ខែ...មាឃ......ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី...០៧.....ខែ...កុម្ភៈ....ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ងួ ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៦៨លើក) មនុស្សចំនួន ១.០៨២នាក់ (ស្រី ៣៩០នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ជាអធិបតីបើកកម្មវិធីកិច្ចពិភាក្សាលើកកម្ពស់សុវត្ថិភាពស្ត្រីនិងកុមារតាមអ៊ីនធឺណិត ដែលរៀបចំដោយក្រុមហ៊ុន Meta និងអង្គការ Auscam Freedom Project គាំទ្រដោយ គ.ជ.ប.ជ។<br>- ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តផែនការប្រចាំឆ្នាំ ២០២២-២០២៣ និងផែនការស្តីពីកិច្ចការពារកុមារឆ្នាំ២០២៣-២០២៤ រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គាំទ្រដោយអង្គការយូនីសេហ្វ មានអ្នកចូលរួម **៦១**នាក់ ស្រី**២៣**នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- ជាអធិបតីក្នុងពិធីអបអរសាទរ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» ដែលរៀបចំដោយ គ.ខ.ប.ជ ខេត្តសៀមរាប។<br>- ជាអធិបតីបើកសិក្ខាសាលាស្តីពី ការប្រមូលជាតុចូលដើម្បីរៀបចំកម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលសហការរៀបចំដោយ គ.ខ.ប.ជ ខេត្តកណ្តាល និងអង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice)។<br>- ជាអធិបតីពីធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដែនដីមនុស្សហូឡង់ដ៏ ប្រចាំកម្ពុជា។<br>- ដឹកនាំក្រុមការងារ គ.ជ.ប.ជ ចុះត្រួតពិនិត្យការងារ និងប្រគល់ឧបករណ៍សោតទស្សន៍(ទូរទស្សន៍ និងឧបករណ៍បំពងសំឡេង) នៅតាមមណ្ឌលទទួលពលករ ច្រកព្រំដែន និងការិយាល័យច្រកចេញ-ចូលតែមួយ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ដោយមានការគាំទ្រដោយអង្គការ UNFPA។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមកិច្ចប្រជុំលើកទី៣ នៃក្រុមការងារបច្ចេកទេសអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (Asean-Act) ដើម្បីប្រមូលជាតុចូលក្នុងការអនុវត្តផែនការសកម្មភាពឆ្នាំ២០២២-២០២៣ ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ របស់ គ ជ.ប.ជ.ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្រសាលី** ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកកិច្ចការអយ្យការនិងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស ASEA-ACT នៅកម្ពុជា មានអ្នកចូលរួម **៣០**នាក់ ស្រី**១៤**នាក់។<br>- ចូលរួមកិច្ចប្រជុំពិភាក្សាកែសម្រួលខ្លឹមសារអនុស្សារណៈយោគយល់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពការពារកុមារ នៃអង្គភាពមូលនិធិកុមារកម្ពុជា ស្តីពីការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជន នៅព្រះរាជាណាចក្រកម្ពុជា មានអ្នកចូលរួម **១៧**នាក់ ស្រី**០៣**នាក់។<br>- ចូលរួមជាគណៈអធិបតី ក្នុងកិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅបំណាច់ឆ្នាំ២០២២ ដែលរៀបចំឡើងដោយក្រុមការងារ ASEAN-ACT នៅសណ្ឋាគារភ្នំពេញ។ |

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២២ច្បាប់ លិខិតចូល ១០ច្បាប់។
  - លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១១ច្បាប់ លិខិតចូល ១៨ច្បាប់។
  - ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ៩០ច្បាប់។
  - អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ២៩សកម្មភាព។
  - អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ២៣ច្បាប់។
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - លោកឧត្តមសេនីយ៍ទោ ***កែវ សុវណ្ណារ៉ា*** អគ្គលេខាធិការរង បានអញ្ជើញធ្វើបទបង្ហាញពាក់ព័ន្ធនឹងការលើកកម្ពស់សុវត្ថិភាពស្ត្រី និងកុមារតាមអ៊ីនធឺណិត នៅសណ្ឋាគារ HYATT REGENCY ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ រៀបចំដោយក្រុមហ៊ុន Meta និង អង្គការ Auscam Freedom Project និងគាំទ្រដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - **លោកប្រធានក្រុម** បានចូលរួម៖ **១**.កិច្ចប្រជុំកែសម្រួលឯកសារចុងក្រោយ ស្ដីពីសុខភាពជនទេសន្តរប្រវេសន៍ ដែលដឹកនាំដោយឯកឧត្តម **ម៉ៅ តាន់អ៊ាង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល នៅJenny cafe។ **២**.សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ស្ដីពីជម្ងឺរបេង អេដស៍ និងជម្ងឺឆ្លងផ្សេងៗ ក្នុងចំណោមជនទេសន្តប្រវេសន៍ និងប្រជាជនចល័ត ក្រោមអធិបតីភាពឯកឧត្តមសាស្ត្រាចារ្យ **ស៊ា ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារកាំបូឌីយ៉ាណា។
  - **ឯកឧត្តម អគ្គលេខាធិការរង៖** **១**.បានចូលរួមកិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ដឹកនាំដោយឯកឧត្តម **គីម សុវណ្ណឌី** អគ្គលេខាធិការក្រុមប្រឹក្សាជាតិដើម្បីកុមារ មានអ្នកចូលរួម **៣០**នាក់ នៅសណ្ឋាគារសាន់វេ។ **២**.បានចូលរួមកម្មវិធីទិវាអន្តរជាតិសម្រាប់ជនទេសន្តប្រវេសន៍ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ឺ វុឌ្ឍី** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានអ្នកចូលរួមប្រហែល **២០០**នាក់ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC)ក្នុងសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ **៣**.បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រដាក់បញ្ចូលយេនឌ័រ និងបរិយាបន្នសង្គមក្នុងការអន្តរាគមន៍អំពើជួញដូរមនុស្សនៅកម្ពុជា ប្រកបដោយប្រសិទ្ធភាព នៅសណ្ឋាគារសាន់វេ។ **៤**.ចូលរួមបើកសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការប្រមូលធាតុចូលដើម្បីរៀបចំកម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅខេត្តកណ្តាល។ **៥**.បានចូលរួមកិច្ចប្រជុំគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើឧបករណ៍ ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ នៅខេត្តសៀមរាប។ **៦**.បានចូលរួមសិក្ខាសាលាស្តីពី ការលើកកម្ពស់ការអនុវត្តសាវាចរណ៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអ.ស.ប និងផែនការឆ្លើយតប ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារកាំបូឌីយ៉ាណា។ ៨

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- ឧត្តមសេនីយ៍ទោ **កែវ ផល្លា** ប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកិច្ចប្រជុំលើកទី៣ នៃក្រុមការងារបច្ចេកទេសអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (Asean-Act) ដើម្បីប្រមូលធាតុចូលក្នុងការអនុវត្តផែនការសកម្មភាពឆ្នាំ២០២២-២០២៣ ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ របស់ គ.ជ.ប.ជ.ក្រោមអធិបតីភាពឯកឧត្តម **ប៉ែន ពេជ្រសាលី** ប្រតិភូរាជរដ្ឋាភិបាល អគ្គនាយកកិច្ចការអយ្យការនិងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស ASEA-ACT នៅកម្ពុជា។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកស្រីវរសេនីយ៍ទោ **ថោង សុវត្ថិ** អនុប្រធានក្រុម៖ ១.បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី "ការលើកកម្ពស់សុវត្ថិភាពស្ត្រី និងកុមារតាមអ៊ិនធឺណិត" នៅសណ្ឋាគារ Hyatt Regency។ ២.ចូលរួមសិក្ខាសាលាស្តីពី"ការប្រមូលធាតុចូលដើម្បីរៀបចំ កម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស" នៅខេត្តកណ្តាល ដែលគាំទ្រដោយអង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice)។

- លោកជំទាវឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង៖ ១.បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីខមមីតលើកទី៥ ក្រោមអធិបតីភាពលោកជំទាវ **ហ៊ូ សាមិត្ត** ប្រធានក្រុមការងារខមមីតកម្ពុជា តាមប្រព័ន្ធអនឡាញ នៅទីស្តីការក្រសួងកិច្ចការនារី មានអ្នកចូលរួម **១១**នាក់ ស្រី០៤នាក់។ ២.បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅបំណាច់ឆ្នាំ២០២២ ដែលរៀបចំដោយក្រុមការងារ ASEAN-ACT នៅសណ្ឋាគារភ្នំពេញ។ ៣.បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពី ការបង្កើតវីដេអូបែបខ្លីអប់រំផ្សព្វផ្សាយពាក់ព័ន្ធករណី Cyber Crime ជាមួយតំណាងអង្គការ A21 និងតំណាងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា របស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

- លោកវរសេនីយ៍ទោ **អោក ភារិន** បានចូលរួម៖ ១.កម្មវិធីយុទ្ធនាការ១៦ថ្ងៃ(រួមគ្នាបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀននៅក្នុងពិភពការងារ) ដែលរៀបចំដោយក្រសួងកិច្ចការនារី និងអង្គការយែប្រចាំកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ **គង់ សំអូន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី នៅសណ្ឋាគារហ៊ីម៉ាវ៉ារីភ្នំពេញ។ ២.សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ស្តីពីជំងឺរបេង អេដ៍ និងជំងឺឆ្លងផ្សេងៗ ក្នុងចំណោមជនទេសន្តរប្រវេសន៍ និងប្រជាជនចល័ត ដែលរៀបចំដោយអង្គការ IOM នៅសណ្ឋាគារកាំបូឌីយ៉ាណា។

- លោកឧត្តមសេនីយ៍ទោ **ស្រី សាមឌី** បានអមដំណើរលោកជំទាវ អគ្គលេខាធិការ ចូលរួមវេទិកាសម្រាប់ជនទេសន្តរប្រវេសន៍ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC)ក្នុងសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**

- លោកឧត្តមសេនីយ៍ត្រី **តែ សុថារេត** អគ្គលេខាធិការរង បានអញ្ជើញ៖ ១.ចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅបំណាច់ឆ្នាំ២០២២ ដែលរៀបចំដោយក្រុមការងារ ASEAN-ACT នៅសណ្ឋាគារភ្នំពេញ។ ២.ចូលរួមកិច្ចប្រជុំលើកទី៧ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ.អ.ផ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា។៕

| លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៤៦លើក អ្នកចូលរួមសរុបចំនួន ៧៣៣នាក់(ស្រី ៣៤៦នាក់) | |
|---|---|
| **ខេត្តសៀមរាប** | - ប្រជុំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រុង-ស្រុក ចំនួន **០៥**លើក អ្នកចូលរួម **១១២**នាក់ ស្រី**៥៣**នាក់។<br>- ក្រុមការងារលេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យខ្លឹមសារមេរៀន សម្រាប់ធ្វើការបណ្តុះបណ្តាលស្តីពី ការថែទាំដោយផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត បានចំនួន **០១**លើក អ្នកចូលរួម **០៧**នាក់ ស្រី**០២**នាក់។<br>- លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំត្រៀមរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ឆ្នាំ២០២២ បានចំនួន **០១**លើក អ្នកចូលរួម **២០**នាក់ ស្រី**០៧**នាក់។ |
| **ខេត្តកណ្តាល** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ និងត្រីមាស **០១**លើក មានអ្នកចូលរួម **៦៣**នាក់ ស្រី**៣៥**នាក់។<br>- ក្រុមការងារក្រុង ស្រុក-ប្រជុំប្រចាំខែ ចំនួន **១១**លើក អ្នកចូលរួម **២៤៨**នាក់ ស្រី**១២៣**នាក់។<br>- ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ៖ **១**.បានចូលរួមក្នុងកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។ **២**.បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ការបង្កើតគណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សគ្រប់ទម្រង់ និងការងារបង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តកំពង់ចាម** | - លោកជំទាវ **ប៉ាង ដានី** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពីយន្តការក្នុងការទទួលពាក្យបណ្តឹង និងគោលការណ៍ណែនាំសម្រាប់ដោះស្រាយវិវាទពលករ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម **៤២**នាក់ ស្រី**២៦**នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកសាងផែនការសកម្មភាព និងយន្តការដោះស្រាយបណ្តឹងរបស់ពលករ ក្រោមអធិបតីភាព លោក **ចេង ហ៊ាង** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានអ្នកចូលរួម **៣១**នាក់ ស្រី**១៤**នាក់ ។ |
| **ខេត្តព្រៃវែង** | - ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ និង លោកជំទាវ **លៀង ស្រីម៉ុល** អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តកំពង់ឆ្នាំង** | - ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ ចំនួន**០១**លើក។<br>- បានចូលរួមសិក្ខាសាលាស្តីពីយុត្តិធម៌អនីតិជន រយៈពេល ២ថ្ងៃ នៅខេត្តសៀមរាប។៚ |

| | |
|---|---|
| **ខេត្តមណ្ឌលគិរី** | - ឯកឧត្តម **ថង សាវុន** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគ.ខ.ប.ជ និងលោកស្រី **រិន ស៊ីផួន** ប្រធានលេខាធិការដ្ឋាន បានចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តបន្ទាយមានជ័យ** | - លោកស្រី **រស់ សុផានី** ប្រធានលេខាធិការដ្ឋាន៖ **១**.បានចូលរួមសម្របសម្រួលសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ស្រាវជ្រាវ ស្តីពីចំណេះដឹង ឥរិយាបថ ការអនុវត្តទាក់ទងនឹងជំងឺអេដស៍ របេង និងជំងឺឆ្លងផ្សេងៗទៀត និងឧបសគ្គក្នុងការទទួលសេវាសុខភាពរបស់ប្រជាជនចំណាកស្រុក និងប្រជាជនចល័ត សរុបអ្នកចូលរួម **៦៥**នាក់ ស្រី**៣៣**នាក់។ **២**.បានចូលរួមសម្របសម្រួលក្នុងកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។<br>- លោក **ឈឿន គ្រៃយ៉ង** ក្រុមការងារសម្របសម្រួលនីតិធី បានចូលរួមសម្របសម្រួលក្នុងកិច្ចប្រជុំពិគ្រោះយោបល់ការទទួលកញ្ចប់ជំនួយសង្គមដល់ជនចំណាកស្រុក និងជនមាតុភូមិនិវត្តន៍ មានអ្នកចូលរួម **៤៥**នាក់ ស្រី**២៧**នាក់។<br>- លោក **លី សុវណ្ណារិទ្ធ** បានចូលរួមប្រជុំស្តីពីការពិនិត្រសេចក្តីព្រាងច្បាប់ពីការបង្កើតក្រុមការងារបច្ចេកទេសសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ក្រោមជាតិ ខេត្តបន្ទាយមានជ័យ មានអ្នកចូលរួម **៣៧**នាក់ ស្រី**០៦**នាក់។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។<br>- បានចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួល ស្តីពីការអនុវត្តផែនការកិច្ចការពារកុមារ ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អាណត្តិទី៣ នៅសាលាខេត្តបាត់ដំបង។<br>- បានចូលរួមផ្តល់កិច្ចសម្ភាសន៍ ជូនក្រុមសិក្សាវាយតម្លៃគម្រោង "សុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា" តាមប្រព័ន្ធអនឡាញ ZOOM ។<br>- បានចូលរួមកម្មវិធីសម្តែងសៀករបស់អង្គការហ្វាពន្លឺសិល្បៈ "អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព" ក្រោមការឧបត្ថម្ភ និងគាំទ្រពីអង្គការការីតាស់ស្វីសកម្ពុជា នៅមណ្ឌលទទួលពលករកំរៀង។<br>- បានអមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចែកសម្ភារៈ និងឧបករណ៍សម្រាប់បំពាក់ផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការការពារពីជំងឺកូវីដ ដែលឧបត្ថម្ភដោយអង្គការ UNFPA ជូនមណ្ឌលទទួលពលករកំរៀង និងច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ស្រុកសំពៅលូន។<br>- បានចុះចែកអំណោយ និងសម្ភារៈប្រើប្រាស់ជូនដល់ប្រជាពលរដ្ឋ និងគ្រួសារដែលធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីអប់រំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព។<br>- បានផ្តល់ជូនសម្ភារៈប្រើប្រាស់មួយចំនួនដល់រដ្ឋបាលស្រុកសំពៅលូន ភ្នំព្រឹក បវេល និងស្រុករុក្ខគិរី ដើម្បីចែកជូនបន្តដល់បងប្អូនពលករដែលវិលត្រលប់មកពីធ្វើការនៅប្រទេសថៃ រឺគ្រួសារពលករ និងធ្វើការផ្សព្វផ្សាយបន្តអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។៨ |

| | |
|---|---|
| | - មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈចូលរួមសិក្ខាសាលា ស្តីអំពីសេវាគាំទ្រពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសារ ០១លើក។ |
| **ខេត្តកោះកុង** | - លោក **ស្រេង ហុង** ប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមទិវាជាតិ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តរតនគិរី** | - ឯកឧត្តម **ញ៉ែម សំអឿន** អភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ និងលោកជំទាវ **ញាន ទិត្យចិន្តា** អភិបាលរង និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានអញ្ជើញចូលរួមទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តក្រចេះ** | - លោកស្រី **ខាំ សុភាព** អភិបាលរង និងជាប្រធានលេខាធិការដ្ឋាន បានចូលរួមកម្មវិធីទិវាជាតិប្រឆាំងការការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ ក្រោមអធិបតីភាព **សម្តេច ក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តកំពង់ធំ** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០២២ និងពិនិត្យលើផែនការសកម្មភាពការងារឆ្នាំ២០២៣ ក្រោមអធិបតីភាពលោកជំទាវ **លំ គន្ធារី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍នៃគ.ខ.ប.ជ មានអ្នកចូលរួម **៦៣**នាក់ ស្រី**២០**នាក់ ។<br>- បានចូលរួមវគ្គសិក្ខាសាលាស្តីពី ការបង្វែរអនីតិជនទំនាស់នឹងច្បាប់ នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប ។<br>- លោកជំទាវ **លំ គន្ធារី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជ បានចូលរួមអបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២២ **សម្តេច ក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលមហោស្រពកោះពេជ្រ។ |